គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៤ ចេញផ្សាយថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០២១
No. 4 Released on July 26, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលកិច្ចពាណិជ្ជកម្ម

## Commercial Trust

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាល-កិច្ចត្រូវបានបែងចែកជា ៤ ប្រភេទ រួមមាន៖ **១. បរធនបាលកិច្ចពាណិជ្ជកម្ម** ២. បរធនបាលកិច្ចសាធារណៈ ៣. បរធនបាលកិច្ចសង្គម និង ៤. បរធនបាលកិច្ចបុគ្គល។ អត្ថបទនេះ នឹងផ្តោតសំខាន់លើបរធនបាលកិច្ចពាណិជ្ជកម្ម ចំណែកឯបរធនបាលកិច្ច ៣ ប្រភេទទៀត នឹងត្រូវបានរៀបរាប់លម្អិតនៅក្នុងប្រធានបទបន្តបន្ទាប់ទៀត។ អ្វីទៅជាបរធនបាលកិច្ចពាណិជ្ជកម្ម? តើវាមានលក្ខណៈដូចម្តេចខ្លះ?

**បរធនបាលកិច្ចពាណិជ្ជកម្ម** ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ឬគោលបំណងផ្សេងទៀត សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬបុគ្គលណាមួយជាក់លាក់ ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនោះ។ លក្ខណៈនៃបរធនបាលកិច្ចពាណិជ្ជកម្មមាន ៣ ធំៗដូចខាងក្រោម៖

១. មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែល ដែលត្រូវបានផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែង ឬវិនិយោគ ដើម្បីជាប្រយោជន៍ដល់ម្ចាស់មូលនិធិ អ្នកផ្តល់វិភាគទាន ឬបុគ្គលផ្សេងទៀត។

២. សេវារក្សាទុកដែលទ្រព្យសម្បត្តិឬមូលនិធិ ត្រូវបានផ្ទេរដោយបុគ្គលណាមួយ ឱ្យទៅបរធនបាលគ្រប់គ្រង និងចាត់ចែង ហើយបរធនបាលនោះ ត្រូវផ្ទេរទ្រព្យសម្បត្តិឬមូលនិធិនោះ ត្រឡប់ទៅបុគ្គលនោះវិញ ឬបុគ្គលណាមួយផ្សេងទៀត។ ការរក្សាទុកនូវទ្រព្យសម្បត្តិឬមូលនិធិនេះ អាចត្រូវបានរក្សាទុកនៅមន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬនៅសេវារក្សាទុកផ្សេងទៀតដែលមានការអនុញ្ញាតពីបញ្ញត្តិករពាក់ព័ន្ធដូចជា ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីគ្រប់គ្រងសកម្មភាពដែលស្ថិតក្រោមតួនាទី និងភារកិច្ចរបស់ខ្លួន *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)* ។

៣. គម្រោងភាគហ៊ុននិយោជិតឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាលគ្រប់គ្រងទ្រព្យសម្បត្តិឬមូលនិធិ ដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩)*។

According to the Law on Trust (2019), there are four types of trust: **1. Commercial Trust**, 2. Public Trust, 3. Social Trust, and 4. Personal Trust. This article will focus mainly on the commercial trust while other three will be elaborated more for the following articles. Therefore, what is Commercial Trust? And its characteristics?

**Commercial trust** is established for the purpose of profit for the benefits of the fund's owner or any specific individual determined by that trust fund's owner. There are three major characteristics of the commercial trust:

1. Pension funds, educational funds and similar funds that were transfered to a trustee to manage and administer or invest for the benefits of the fund's owner, donor or other person.

2. Depository services of asset or funds can be transfered to a trustee to manage and administer, and that trustee needs to transer those asset and funds to its owner or other individual. Such depository of this asset or fund may be kept at a notary office or law firm or accounting firm or at other depository services permitted by the relevant authorities such as National Bank of Cambodia (NBC), Securities and Exchange Regulator of Cambodia (SERC), or Ministry of Economic and Finance (MEF) in order to manage and perform their roles and duties. *(Law on Trust, 2019).*

3. Employee stock option plan or employee's benefits that a trustee manage the asset or funds to invest on their behalf *(Law on Trust, 2019)*.

**ឯកសារយោង | References**:

- ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

**អត្ថបទ៖ ហាយ សុវណ្ណា | Article: Hay Sovanna**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.